# សុន្ទរកថាស្វាគមន៍ និងរបាយការណ៍វឌ្ឍនភាពការងារ
# ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន
# និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
# ក្នុងពិធីបើក «សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៧
# និងទិសដៅការងារឆ្នាំ២០១៨»

ថ្ងៃច័ន្ទ ៨រោច ខែមិគសិរ ឆ្នាំរកា ព.ស ២០៦១

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែធ្នូ គ.ស ២០១៧

- *ជាបឋម ខ្ញុំបាទសូមគោរពឯកឧត្តម* ***ប៊ិន ឈិន*** *ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរព!*
- *សូមគោរព ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មការនៃព្រឹទ្ធសភា និងរដ្ឋសភា ដ៏ឧត្តុង្គឧត្តម!*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងបរិស្ថាន តំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!*

ថ្ងៃនេះ តាងនាមឱ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងបរិស្ថាន ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមគោរពស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់កិត្តិយសអញ្ជើញជាអធិបតីក្នុងពិធីបើក **«សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨»** នាពេលនេះ។ ខ្ញុំបាទសូមយកឱកាសនេះ គោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធីបើកសន្និបាតនេះ ដែលញ៉ាំងឱ្យអង្គពិធីទាំងមូលប្រព្រឹត្តទៅប្រកបដោយភាពអធឹកអធមក្រៃលែង។

ជាមួយគ្នានេះដែរ ជំនួសមុខឱ្យគណៈកម្មការរៀបចំសន្និបាត ខ្ញុំបាទក៏សូមគោរពស្វាគមន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មការនៃព្រឹទ្ធសភា និងរដ្ឋសភា ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានឆ្លៀតពេលដ៏មមាញឹក អញ្ជើញចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីបើកសន្និបាតដ៏មានសារៈសំខាន់នេះ។

- ***ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការជាទីគោរពដ៏ខ្ពង់ខ្ពស់!***
- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីគោរពរាប់អាន!***

សន្និបាតបូកសរុបលទ្ធផលការងារ ជាកិច្ចការដែលគ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំឡើងជារៀងរាល់ឆ្នាំ ដើម្បីពិនិត្យវាយតម្លៃវឌ្ឍនភាពការងារនិងសមិទ្ធផលសម្រេចបានក្នុងឆ្នាំកន្លងមក ស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានា និងលើកទិសដៅការងារអាទិភាពសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់។ ដោយឡែក សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំនេះ គឺមិនត្រឹមតែជាការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ប៉ុណ្ណោះទេ

ប៉ុន្តែថែមទាំងជាការពិនិត្យវាយតម្លៃវឌ្ឍនភាពការងារសម្រាប់រយៈពេល៤ឆ្នាំ ដែលក្រសួងបរិស្ថានសម្រេចបានចាប់តាំងពីដើមអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា។

តាមរយៈសន្និបាតឆ្នាំនេះ ក្រសួងបរិស្ថាននឹងដាក់ចេញនូវយុទ្ធសាស្ត្រ ផែនការសកម្មភាព និងទិសដៅការងារអាទិភាព សម្រាប់ឱ្យគ្រប់អង្គភាពក្រោមឱវាទក្រសួងបរិស្ថានបន្តអនុវត្ត ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបរិស្ថាន សំដៅប្រមូលផ្តុំកម្លាំងមហាជនពីគ្រប់មជ្ឈដ្ឋានឱ្យចូលរួមកាន់តែសកម្មបន្ថែមទៀតក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព។ ជារួម សន្និបាតឆ្នាំ២០១៧នេះ មានចរិតលក្ខណៈជាការបូកសរុបសមិទ្ធផលធំៗ ក្នុងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់កំណត់ទិសដៅការងារអាទិភាពក្នុងវិស័យនេះនៅក្នុងអាណត្តិបន្ទាប់ សំដៅឆ្លើយតបទៅនឹងដំណើរវិវត្តន៍នៃនិន្នាការនយោបាយ ស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ទាំងនៅថ្នាក់ជាតិ តំបន់ និងពិភពលោក ។

ខ្ញុំបាទសូមយកឱកាសនេះ គោរពជម្រាបជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ និងអង្គសន្និបាតទាំងមូលមេត្តាជ្រាបថា ដោយផ្អែកលើ «*គោលនយោបាយគណបក្សប្រជាជនកម្ពុជា ដើម្បីកសាង និងការពារមាតុភូមិ ឆ្នាំ២០១៣-២០១៨ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល និងមតិណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គលើកទី១ របស់គណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣*» ក្រសួងបរិស្ថានបានកំណត់យក «ការធ្វើទំនើបកម្មស្ថាប័ន កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព» ជាសសរស្តម្ភ និងជាមូលដ្ឋានគ្រឹះ សម្រាប់ការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍដោយចីរភាព ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់អង្គការសហប្រជាជាតិ។

ជាក់ស្តែង គិតត្រឹមចុងឆ្នាំ២០១៧នេះ ក្រសួងបរិស្ថានបានសម្រេចលទ្ធផលការងារសំខាន់ៗដូចខាងក្រោម៖

**១. ការធ្វើទំនើបកម្មស្ថាប័ន៖** ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយរបស់រាជរដ្ឋាភិបាល និងជាមូលដ្ឋានសម្រាប់ពង្រឹងប្រសិទ្ធភាពនៃកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព ក្រសួងបានធ្វើទំនើបកម្មស្ថាប័ន ដោយផ្តោតការយកចិត្តទុកដាក់លើការងារជាអាទិភាពដូចខាងក្រោម៖

ក. កំណែទម្រង់ស្ថាប័ន គោលនយោបាយ និងច្បាប់

- ក្រសួងបានធ្វើការកែសម្រួលរចនាសម្ព័ន្ធក្រសួងបរិស្ថាន រួមមាន អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន អគ្គាធិការដ្ឋាន និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង តាមរយៈអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន។ ទន្ទឹមនឹងនេះ ក្រសួងបរិស្ថានក៏បានពិនិត្យ និងកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរបរិស្ថានរាជធានី ខេត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។
- ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបានបង្កើតឡើង តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ដោយធ្វើសមាហរណកម្មតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ និងគណៈកម្មាធិការជាតិជីវសុវត្ថិភាព

ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការរៀបចំ និងអនុវត្តគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ និងការកៀរគរធនធានថវិកា និងបច្ចេកទេស សម្រាប់លើកកម្ពស់ការអភិវឌ្ឍបៃតង ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព សំដៅធានាបាននូវតុល្យភាពរវាងការអភិរក្ស និងការអភិវឌ្ឍ។

- ក្រសួងបានរៀបចំ «យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣» ដែលជាផែនទីបង្ហាញផ្លូវសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព តាមរយៈ ការជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធដាក់បញ្ចូលបញ្ហាបរិស្ថាន និងធនធានធម្មជាតិទៅក្នុងផែនការ និងកម្មវិធីអភិវឌ្ឍន៍ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ក្រសួងក៏បានរៀបចំសេចក្តីព្រាង «ក្រមបរិស្ថាន និងធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា» ដែលជាក្របខណ្ឌគតិយុត្តមួយគ្របដណ្តប់លើវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយធ្វើសមាហរណកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ខ. ការអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមថវិកាកម្មវិធី៖ ក្រសួងបានជំរុញការអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមថវិកាកម្មវិធី ដោយបង្កើតអង្គភាពថវិកាចំនួន៣០ ដើម្បីធានាគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងសង្គតិភាពថវិការដ្ឋ ក៏ដូចជា ការផ្តល់សេវាសាធារណៈតាមការិយាល័យច្រកចេញចូលតែមួយ ព្រមទាំងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុបែបថ្មី សំដៅធានាប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ និងការពង្រឹងការចុះបញ្ជីសារពើភ័ណ្ឌចលនទ្រព្យ និងអចលនទ្រព្យរបស់រដ្ឋ។

គ. ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការផ្ទេរមុខងារ

- ក្រសួងបានផ្ទេរមុខងារចំនួន៥ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន ១. ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ២. ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ៣. ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ៤.ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ និង ៥. ការពង្រឹងការងារអប់រំបរិស្ថាន។ នៅពាក់កណ្តាលឆ្នាំ២០១៧នេះ ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួងបរិស្ថានបានចុះតាមដាន ត្រួតពិនិត្យ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារ ដើម្បីធានាការអនុវត្តតាមច្បាប់ លិខិតបទដ្ឋាន និងសេចក្តីណែនាំនានាក្នុងការផ្តល់សេវាតាមបែបវិមជ្ឈការ។
- ក្រសួងក៏បានចុះត្រួតពិនិត្យ អង្កេតស្រាវជ្រាវ និងធ្វើអធិការកិច្ចលើករណីបណ្តឹង និងភាពមិនប្រក្រតីនានា ដើម្បីពង្រឹងការគ្រប់គ្រង និងដឹកនាំនៅតាមមន្ទីរបរិស្ថាន និងតំបន់ការពារធម្មជាតិ និងបានចុះធ្វើសវនកម្មលើអង្គភាពរងសវនកម្ម និងនៅតាមមន្ទីរបរិស្ថានរាជធានី ខេត្ត។

ឃ. ការគ្រប់គ្រងធនធានមនុស្ស និងកិច្ចគាំពារសុខុមាលភាពមន្ត្រីរាជការ

- បានយកចិត្តទុកដាក់លើកិច្ចគាំពារមន្ត្រីរាជការ លើកទឹកចិត្តមន្ត្រីសកម្ម និងគិតគូរជាចម្បងដល់ជីវភាព និងទុក្ខលំបាករបស់មន្ត្រីរាជការ ដូចជាឧបត្ថម្ភសម្រាប់ការរៀបអាពាហ៍ពិពាហ៍ ការសម្រាលបុត្រ ការចូលនិវត្តន៍ ការព្យាបាលជម្ងឺ មរណភាព និងជីវភាពខ្វះខាត។

- ក្រសួងបានធ្វើដំឡើងមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងរៀបចំប្រកាសទទួលក្របខណ្ឌមន្ត្រីរាជការថ្មី មន្ត្រីផ្ទេរពីក្រសួងស្ថាប័នផ្សេងៗ និងការតែងតាំងមន្ត្រីរាជការឱ្យបានត្រឹមត្រូវ ស្របតាមសមត្ថភាពវិជ្ជាជីវៈ។
- ក្រសួងក៏បានកសាង និងពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងនិងក្រៅប្រទេសស្ដីពីជំនាញរដ្ឋបាល-ហិរញ្ញវត្ថុ ជំនាញឯកទេស និងផ្ដល់ឱកាសឱ្យទទួលបានអាហារូបករណ៍ថ្នាក់ឧត្តម និងក្រោយឧត្តមនៅក្រៅប្រទេស។

ង. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការផ្គត់ផ្គង់មធ្យោបាយ និងសម្ភារៈ

- បានសាងសង់ទីស្ដីការក្រសួងបរិស្ថានថ្មី «អគារមេតរកតេជោ» ដោយបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- បានបំពាក់រថយន្តចំនួន ១០៩គ្រឿង ដោយមិនប្រើប្រាស់ថវិការដ្ឋ និងបានចែកជូនចាប់ពីរដ្ឋលេខាធិការដល់ប្រធាននាយកដ្ឋាននៅថ្នាក់ជាតិ និងប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត។
- បានទិញម៉ូតូចំនួន ៣០គ្រឿង ជូនតំបន់ការពារធម្មជាតិ និង ៣៥គ្រឿង អំណោយរបស់ក្រុមហ៊ុន ទ្រី ភាព ជូនមន្ត្រីនាយកដ្ឋានចំណុះក្រសួង ដើម្បីប្រើប្រាស់។
- បានបំពាក់សម្ភារៈការិយាល័យនានា ជូនថ្នាក់ដឹកនាំ អគ្គនាយកដ្ឋាន និងនាយកដ្ឋាន ដូចជា Laptop Computer ចំនួន ៩២គ្រឿង Desktop Computer ចំនួន ២៨១គ្រឿង ម៉ាស៊ីន Printer ចំនួន ១១៨គ្រឿង និងម៉ាស៊ីនថតចម្លង ចំនួន ៣២គ្រឿង។
- បានផ្ដល់សម្លៀកបំពាក់ជាឯកសណ្ឋានជូនមន្ត្រីរាជការ និងមន្ត្រីឧទ្យានុរក្ស។

**២. កិច្ចគាំពារបរិស្ថាន៖** ក្រសួងបានខិតខំអនុវត្តតួនាទីរបស់ខ្លួនដោយស្មារតីទទួលខុសត្រូវ ដើម្បីធានាបរិស្ថានស្អាត និងបៃតង សំដៅលើកកម្ពស់សុខុមាលភាពសាធារណៈ ដោយសម្រេចបាននូវភារកិច្ចស្នូលសំខាន់ៗមានជាអាទិ៍៖

- បានជំរុញការអនុវត្ត ១.អនុក្រឹត្យស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២.អនុក្រឹត្យស្ដីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ៣.អនុក្រឹត្យស្ដីពីការបង្កើតមូលនិធិបរិស្ថាននិងសង្គម និង៤. អនុក្រឹត្យស្ដីពីការគ្រប់គ្រងថង់ប្លាស្ទីក។
- បានបញ្ចប់សេចក្ដីព្រាង៖ ១. អនុក្រឹត្យស្ដីពីការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ២. អនុក្រឹត្យស្ដីពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យការសាយភាយនិងបំលាស់ទីសារធាតុបំពុល។
- បានបញ្ចប់សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងសំណល់នៅកម្ពុជា ២០១៧-២០៣០ ក្នុងគោលដៅធានាការគ្រប់គ្រងសំណល់តាមវិធីសាស្ត្រចម្រុះ ស្របតាមទស្សនាទាន «ការអភិវឌ្ឍទីក្រុងដោយនិរន្តរភាព»។
- បានរៀបចំបង្កើត និងអនុវត្តកញ្ចប់ថវិកាសេវាអនាម័យ បរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង-រាវ តាមក្រុងគោលដៅចំនួន ២៦ ចាប់តាំងពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ ដែលមានថវិកាសរុបចំនួន ២១៣ពាន់លានរៀល និងបានចុះតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសការអនុវត្តការផ្ទេរមុខងារ និងការប្រើប្រាស់ថវិកាឱ្យកាន់តែមានប្រសិទ្ធភាព និងគណនេយ្យភាព។

- បានពង្រឹងប្រសិទ្ធភាព និងពន្លឿនដំណើរការពិនិត្យផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម និងបានចុះតាមដានត្រួតពិនិត្យការអនុវត្តលិខិតបទដ្ឋានគតិយុត្តបំពុលបរិស្ថាន និងលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យាការពារបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន។
- បានតាមដានត្រួតពិនិត្យគុណភាពទឹក ដី ខ្យល់ និងកម្រិតអាស៊ីដបរិយាកាស នៅតាមបណ្តាទីប្រជុំជន រាជធានី និងខេត្តគោលដៅ ដើម្បីជានាធ្វើការវាយតម្លៃពីស្ថានភាពគុណភាពបរិស្ថាន។
- បានសហប្រតិបត្តិការក្នុងក្របខណ្ឌតំបន់ ដើម្បីពង្រឹងសមត្ថភាព និងសុក្រឹត្យភាពវិភាគរបស់មន្ទីរពិសោធន៍។
- បាន និងកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍ និងបណ្តាប្រទេសជាមិត្ត ក្នុងការរៀបចំ និងអនុវត្តគម្រោង និងសកម្មភាពនានាពាក់ព័ន្ធកិច្ចគាំពារបរិស្ថាន។

**៣. ការងារការពារ និងអភិរក្សធនធានធម្មជាតិ៖** ដើម្បីពង្រឹងការការពារ និងអភិរក្សធនធានធម្មជាតិ ក្រសួងបរិស្ថានបានខិតខំអនុវត្តឱ្យសម្រេចបានជោគជ័យលើការងារអាទិភាពដូចខាងក្រោម៖

- បានរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិចាំបាច់នានា ដើម្បីពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ដែលរួមមាន៖ អនុក្រឹត្យ សារាចរ ប្រកាសរួម ផែនការយុទ្ធសាស្ត្រជាតិ និងគោលការណ៍ណែនាំផ្សេងៗ ដែលមានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ។
- បានអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការផ្ទេរគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចចំនួន៧៣ ពីក្រសួងបរិស្ថានទៅឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្ទេរតំបន់ព្រៃការពារចំនួន ១៣កន្លែង និងព្រៃផ្តល់ផលចំនួន ៥កន្លែង ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មកក្រសួងបរិស្ថាន។
- បានសហការជាមួយគណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសធនធានធម្មជាតិ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដឹកនាំសម្របសម្រួល និងចាត់វិធានការ ស្របតាមគោលការណ៍ច្បាប់ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ។
- បានយកចិត្តទុកដាក់បង្កើនប្រាក់ឧបត្ថម្ភប្រចាំខែដល់មន្ត្រីឧទ្យានុរក្ស ពី១៤ម៉ឺនរៀល ដល់ ៤០ម៉ឺនរៀល និងបានជ្រើសរើសមន្ត្រីឧទ្យានុរក្សចំនួន ៣០០នាក់បន្ថែម តាមការសម្រេចរបស់រាជរដ្ឋាភិបាល ព្រមទាំងបានបញ្ចូលមន្ត្រីឧទ្យានុរក្សចំនួន ១.២៦០នាក់ ទៅក្នុងក្របខណ្ឌមុខងារសាធារណៈ។
- បានបង្កើនតំបន់ការពារធម្មជាតិពី ២៣កន្លែង ដល់ ៥០កន្លែង និងបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ៣កន្លែង ដែលគ្រប់ដណ្តប់លើផ្ទៃដីប្រមាណ ៧,៥ លានហិកតា ស្មើនឹង ៤១% នៃផ្ទៃប្រទេស។
- បានសិក្សាស្រង់ទិន្នន័យ និងវាយតម្លៃសក្តានុពលជីវៈចម្រុះនិងធនធានធម្មជាតិ តំបន់មួយចំនួនដើម្បីបង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែមទៀត។

- បានយកចិត្តទុកដាក់ពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងមន្ត្រីឧទ្យានុរក្ស ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទ ក្នុងតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងនីតិវិធីនៃច្បាប់ជាធរមាន។
- បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងជំរុញការផ្ទេរមុខងារគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិទៅឱ្យថ្នាក់ក្រោមជាតិ ក្រោមការដឹកនាំរួមរបស់គណៈបញ្ជាការឯកភាពខេត្ត ដោយមានមន្ទីរបរិស្ថានជាសេនាធិការ។
- សហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំផែនទីឯកភាព សម្រាប់ពង្រឹងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដូចជា ដីលំនៅដ្ឋាន សម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច តំបន់អភិរក្ស និងតំបន់ការពារធម្មជាតិ។
- បាននិងកំពុងសិក្សាប្រមូលទិន្នន័យព័ត៌មានភូមិសាស្ត្រ និងបកប្រែទិន្នន័យពីផ្កាយរណប ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីតំបន់ការពារធម្មជាតិឡើងវិញ។
- បានរៀបចំកំណត់តំបន់គ្រប់គ្រង រៀបចំផែនការគ្រប់គ្រង និងបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិ។
- សហការរៀបចំនិងអនុវត្តគម្រោងរេដបូកជាមួយអង្គការដៃគូ រួមមានៈ ១.អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) នៅដែនជម្រកសត្វព្រៃ «កែវសីមា» ២.អង្គការអភិរក្សអន្តរជាតិ (CI) នៅដែនជម្រកសត្វព្រៃ«ព្រៃឡង់» និង ៣.អង្គការសម្ព័ន្ធសត្វព្រៃ (WA) នៅឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង និងដែនជម្រកសត្វព្រៃតាតៃ ដើម្បីកៀរគរធនធានថវិកា និងបច្ចេកទេស សម្រាប់ពង្រឹងការការពារ និងអភិរក្សធនធានធម្មជាតិ និងលើកស្ទួយជីវភាពសហគមន៍មូលដ្ឋាន។
- រៀបចំវេទិកាថ្នាក់ក្រោមជាតិស្តីពី «ការការពារនិងអភិរក្សធនធានធម្មជាតិ» រវាងរាជរដ្ឋាភិបាល និង គ្រប់ភាគីពាក់ព័ន្ធ ជាពិសេសអង្គការដៃគូ ដើម្បីពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងធនធានធម្មជាតិ និងលើកស្ទួយជីវភាពសហគមន៍មូលដ្ឋាន ព្រមទាំងបានរៀបចំកិច្ចប្រជុំទូលាយសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា ដើម្បីកាត់បន្ថយការលើកយកបញ្ហាបរិស្ថានជារបៀបវារៈនយោបាយ និងបង្កើនប្រសិទ្ធភាពការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ តំបន់ព្រៃឡង់ និងតំបន់ការពារធម្មជាតិភូមិភាគឦសាន។
- បានធ្វើបច្ចុប្បន្នភាពសហគមន៍តំបន់ការពារធម្មជាតិចំនួន ១៥២ និងកំពុងបន្តនីតិវិធីបង្កើតសហគមន៍តំបន់ការពារធម្មជាតិថ្មីចំនួន ១៧បន្ថែមទៀត។
- បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ លក្ខន្តិកៈ និងយន្តការសម្របសម្រួលសហគមន៍ ដើម្បីចងក្រងសហគមន៍តំបន់ការពារធម្មជាតិឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- បានបណ្តុះបណ្តាលសមាជិកសហគមន៍តំបន់ការពារធម្មជាតិលើផ្នែកកសិកម្ម ចិញ្ចឹមសត្វ សេវាកម្មទេសចរណ៍ធម្មជាតិ ព្រមទាំងបានផ្តល់គ្រាប់ពូជបន្លែ ពូជសត្វ សម្ភារៈចិញ្ចឹមសត្វ សម្ភារៈផ្តល់សេវាកម្មទេសចរណ៍ធម្មជាតិ ផ្ទាំងកញ្ចក់ពន្លឺព្រះអាទិត្យ ប្រព័ន្ធនិងអាងស្តុកទឹក សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ល។ ដើម្បីលើកកម្ពស់ជីវភាពសហគមន៍តំបន់ការពារធម្មជាតិ។

- បានផ្តល់គ្រាប់ពូជឈើដល់សហគមន៍ ដើម្បីបង្កើតថ្នាលបណ្តុះកូនឈើ និងដាំកូនឈើព្រៃ ចំនួន ៥សែនដើម នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងទីសាធារណៈនានា។
- បានបំពេញនិតិវិធីច្បាប់ និងពង្រឹងការគ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ និងសហគមន៍ទេសចរណ៍ធម្មជាតិ ចំនួន៣០ទីតាំង។
- បានធ្វើបច្ចុប្បន្នភាពតំបន់មានសក្តានុពលទេសចរណ៍ធម្មជាតិចំនួន ៩៧ កន្លែង និងកំពុងរៀបចំបង្កើតរបៀងទេសចរណ៍ធម្មជាតិតំបន់ការពារធម្មជាតិ។
- បាននិងកំពុងសិក្សាប្រមូលទិន្នន័យទីតាំងប្រាសាទ និងបុរាណស្ថានចំនួន ៦៥កន្លែង ក្នុងតំបន់ការពារធម្មជាតិ ដោយសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីចងក្រងសៀវភៅ «បញ្ជីសារពើភណ្ឌនៃប្រាសាទបុរាណនិងបុរាណស្ថាន ឆ្នាំ២០១៩»។

**៤. ការអភិវឌ្ឍដោយចីរភាព៖** ដើម្បីធានាការអភិវឌ្ឍ ដែលមានតុល្យភាពរវាងបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបាននិងកំពុងផ្តោតការយកចិត្តទុកដាក់លើការងារជាអាទិភាពដូចខាងក្រោម៖

- ពង្រឹងសមត្ថភាពស្ថាប័នរបស់ក្រុមប្រឹក្សាជាតិ តាមរយៈការរៀបចំ និងដំណើរការនូវអង្គភាពចំណុះអន្តរក្រសួង ក៏ដូចជារចនាសម្ព័ន្ធគ្រប់គ្រងការអភិវឌ្ឍដោយចីរភាពនៅថ្នាក់ក្រោមជាតិ។
- បន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យរបស់ក្រសួង ស្ថាប័ន ចំនួន១៤ និងថ្នាក់ក្រោមជាតិ ដោយខិតខំកៀរគរហិរញ្ញប្បទានអាកាសធាតុពីប្រភពក្នុងស្រុក និងអន្តរជាតិ។
- សិក្សាវាយតម្លៃអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើសេដ្ឋកិច្ចជាតិ នាពេលអនាគត និងផ្តល់អនុសាសន៍សំខាន់ៗទាក់ទងនឹងវិធានការឆ្លើយតប។
- សម្របសម្រួលការអនុម័តផែនការយុទ្ធសាស្ត្រទីក្រុងបៃតង សម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៦-២០២៥ និងបន្តគាំទ្រកម្មវិធីអភិវឌ្ឍន៍ទីប្រជុំជនបៃតង ដោយផ្តោតលើទីក្រុងរដ្ឋបាលចំនួន៧ជាជំហានដំបូង។
- ផ្តល់ធាតុចូលពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង ជាពិសេសការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ឯកសារផែនការជាតិបន្តវេននៅដំណាក់កាលបន្តបន្ទាប់ ជាអាទិ៍ យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣។
- បន្តសម្របសម្រួល និងកៀរគរធនធាន ដើម្បីអនុវត្តយុទ្ធសាស្ត្រ និងផែនការជាតិនានា ពាក់ព័ន្ធនឹងជីវៈចម្រុះ។
- ជំរុញការអនុវត្តយុទ្ធសាស្ត្ររេដបូក (REDD+) ជាតិ ដើម្បីកៀរគរធនធានសម្រាប់លើកកម្ពស់កិច្ចការពារព្រៃឈើ និងជីវភាពសហគមន៍។
- រៀបចំគោលនយោបាយស្តីពី «ការទូទាត់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី» ដោយផ្តោតលើធនធានទឹកជាជំហានដំបូង និងតាមរយៈការអនុវត្តគម្រោងសាកល្បងនៅប្រភពទឹកសំខាន់ៗមួយចំនួន
- រៀបចំកម្មវិធីស្រាវជ្រាវថ្នាក់ជាតិដោយផ្តល់អាទិភាពលើប្រធានបទសំខាន់ៗ សម្រាប់គាំទ្រការរៀបចំគោលនយោបាយ និងផែនការអភិវឌ្ឍន៍ជាតិ។

- បន្តសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-រុស្ស៊ី និងកម្ពុជា-ចិន ក្នុងការប្រើប្រាស់បច្ចេកវិទ្យានុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ដោយផ្តល់អាទិភាពលើការកសាងធនធានមនុស្សជាជំហានដំបូង។
- បន្តជំរុញការប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ ជាពិសេសថាមពលពន្លឺព្រះអាទិត្យ និងបច្ចេកវិទ្យាប្រសិទ្ធភាពថាមពល ដើម្បីគាំទ្រដល់សន្តិសុខថាមពលជាតិ ក៏ដូចជាបង្កើនអត្រាផ្គត់ផ្គង់អគ្គិសនីពីប្រភពថាមពលកកើតឡើងវិញ។
- សម្របសម្រួលការអនុវត្តគម្រោងឥណទានកាបូនរួមគ្នាជាមួយភាគីជប៉ុន ក្នុងការតម្លើងអំពូលបំភ្លឺផ្លូវ LED នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប។
- ជំរុញការអប់រំ និងការលើកកម្ពស់ការយល់ដឹង ពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង ការប្រែប្រួលអាកាសធាតុ និងការអភិរក្សជីវៈចម្រុះ ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយផ្តល់អាទិភាពដល់ការបង្កើតសារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិមួយនៅរាជធានីភ្នំពេញ។

**៥. ការងារអប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន៖** ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព ក្រសួងបរិស្ថានបានយកចិត្តទុកដាក់លើការងារជាអាទិភាពដូចខាងក្រោម៖

- បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបញ្ចូលការអប់រំបរិស្ថានទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត អំពីសុខភាពបរិស្ថាន ការគ្រប់គ្រងសំណល់ ជីវៈសុវត្ថិភាព ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព។
- បានរៀបចំ និងជំរុញការអនុវត្តគោលការណ៍ណែនាំជាតិស្តីពីសាលាមេត្រីបរិស្ថាននៅតាមសាលារៀនចំណេះទូទៅ។
- បានរៀបចំកម្មវិធី និងព្រឹត្តិការណ៍បរិស្ថានជាច្រើន ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ។
- បានរៀបចំវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពគ្រូបង្គោលអប់រំបរិស្ថាន ក្រុមអ្នកនិពន្ធសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងជនបង្គោលព័ត៌មានបរិស្ថានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- បានធ្វើប្រតិភូកម្មមុខងារអប់រំនិងផ្សព្វផ្សាយព័ត៌មានបរិស្ថាន ជូនរដ្ឋបាលរាជធានី ខេត្ត ទាំង២៥ ដើម្បីបង្កើនការងារអប់រំផ្សព្វផ្សាយព័ត៌មានបរិស្ថានឱ្យបានទូលំទូលាយ។
- បានសហការជាមួយអង្គការជាតិ អន្តរជាតិ និងវិស័យឯកជន ក្នុងការរៀបចំព្រឹត្តិការណ៍បរិស្ថាន និងបានជ្រើសរើសសាលាមេត្រីបរិស្ថានឆ្នើមចំនួន២ ដើម្បីទទួលពានរង្វាន់សាលាមេត្រីបរិស្ថានអាស៊ាន។
- បាននិងកំពុងរៀបចំផែនទីប្រព័ន្ធអេកូឡូស៊ីចម្រុះ ដោយប្រមូលនិងចងក្រងនូវទិន្នន័យព័ត៌មានភូមិសាស្ត្របរិស្ថាន ដើម្បីកសាងប្រព័ន្ធគាំទ្រសេចក្តីសម្រេចចិត្ត សំដៅជួយសម្រួលដល់ការប្រើប្រាស់ដីប្រកបដោយចីរភាព។
- បានសហការជាមួយគ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ក្នុងការប្រមូលទិន្នន័យ និងព័ត៌មានបរិស្ថាន ដើម្បីរៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថានជាតិ។

- បានរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងទិន្នន័យព័ត៌មានភូមិសាស្ត្រវិស័យបរិស្ថាន។

សមិទ្ធផលទាំងនេះ គឺបានមកពីកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងបរិស្ថាន និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងភាពជាម្ចាស់លើកិច្ចការដ៏មានសារៈសំខាន់នេះ។ សមិទ្ធផលទាំងនេះពិតជាមិនអាចសម្រេចបានដោយមិនមានការចូលរួម និងកិច្ចសហការពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពជុំវិញខេត្ត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រជាសហគមន៍មូលដ្ឋាននោះឡើយ។

*- ឯកឧត្តមឧបនាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់!*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីគោរពរាប់អាន!*

ក្នុងដំណើរការនៃសន្និបាតរយៈពេលបីថ្ងៃនេះ ក្រសួងបានរៀបចំសិក្ខាសាលាបច្ចេកទេសចំនួន៦ ក្រោមប្រធានបទខុសៗគ្នា ទៅតាមអង្គភាពនីមួយៗចំណុះឱ្យក្រសួងបរិស្ថាន ដោយមានការដឹកនាំនិងសម្របសម្រួលពីសំណាក់ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងអគ្គនាយកទទួលបន្ទុក។ សិក្ខាសាលាទាំង៦នេះនឹងប្រព្រឹត្តទៅនៅតាមទីកន្លែងរៀងៗខ្លួន ក្នុងពេលតែមួយ ក្នុងគោលបំណងពិនិត្យវាយតម្លៃរបាយការណ៍លទ្ធផលការងារតាមជំនាញរបស់ខ្លួន និងដើម្បីប្រមូលផ្តុំនូវគំនិត ទស្សនៈ មតិយោបល់ តាមរយៈការបើកឱ្យមានកិច្ចពិភាក្សា ផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង មេរៀន និងបទពិសោធ រវាងអ្នកគូសវាសគោលនយោបាយ មន្ត្រីជំនាញ អ្នកស្រាវជ្រាវ ប្រតិបត្តិករ និងភាគីពាក់ព័ន្ធ ដោយរំលេចឱ្យឃើញនូវវឌ្ឍនភាពការងាររយៈពេល ៤ឆ្នាំកន្លងមក សម្រាប់ជាធាតុចូលនិងជាមូលដ្ឋានគ្រឹះតម្រង់ទិសដៅការងារអនុវត្តបន្តក្នុងឆ្នាំខាងមុខ។ ប្រធានបទនៃសិក្ខាសាលាទាំង៦នោះ រួមមានៈ ទី១. សិក្ខាសាលាស្តីពីកិច្ចគាំពារបរិស្ថាន ទី២. សិក្ខាសាលាស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ ទី៣. សិក្ខាសាលាស្តីពីការគ្រប់គ្រងការអភិវឌ្ឍដោយចីរភាព ទី៤. សិក្ខាសាលាស្តីពីការគ្រប់គ្រងចំណេះដឹង និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន និងទី៥. សិក្ខាសាលាស្តីពីការពង្រឹងអភិបាលកិច្ចល្អ និងទី៦. សិក្ខាសាលាស្តីពីការអភិរក្សតំបន់បេតិកភណ្ឌ ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងការលើកកម្ពស់ជីវភាពសហគមន៍។

ដោយសន្និបាតឆ្នាំនេះ មានលក្ខណៈជាសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថាន៤ឆ្នាំ ក្នុងអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា និងជាការត្រៀមលក្ខណៈបន្តនិរន្តរភាពដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ខ្ញុំបាទសូមយកឱកាសនេះសម្តែងនូវសមានចិត្តគាំទ្រ និងសូមគាំទ្រលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ អញ្ជើញមកពីគ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ក្នុងការរួមចំណែកពិនិត្យ ពិភាក្សា ផ្តល់យោបល់ និងចែករំលែកបទពិសោធចំណេះដឹងឱ្យបានផុលផុស និងស៊ីជម្រៅលើការងារជំនាញនីមួយៗ ទាំងកម្រិតគោលនយោបាយ និងបច្ចេកទេស ដើម្បីឱ្យសិក្ខាសាលាបច្ចេកទេសទាំង៦នេះ ប្រព្រឹត្តទៅដោយភាពរលូន សម្រេចបានលទ្ធផលជាផ្លែផ្កា និងជាឧត្តមប្រយោជន៍សម្រាប់ការប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៃរដ្ឋសភា។

មុននឹងបញ្ចប់ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងបរិស្ថាន ខ្ញុំបាទសូមយកឱកាសនេះគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្តងទៀតចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ

និងជារដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មមាញឹកអញ្ជើញចូលរួមក្នុងពិធីដ៏មានសារៈសំខាន់នាពេលនេះ ហើយខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន ដើម្បីបុព្វហេតុបរិស្ថាន ពោលគឺកិច្ចសហការរួមគ្នា ដើម្បីកសាងសង្គមកម្ពុជាមួយ ប្រកបដោយបរិស្ថានល្អស្អាត ស្រស់បំព្រង សុខុមាលភាពសង្គម តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី និងការអភិវឌ្ឍដោយចីរភាព។

ជាទីបញ្ចប់ ក្នុងឱកាសឆ្នាំថ្មី ឆ្នាំសកល ដែលនឹងឈានចូលមកដល់ឆាប់ៗនេះ ខ្ញុំបាទសូមគោរពជូនពរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គពិធីទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ សុខភាពល្អ សុភមង្គលគ្រប់ក្រុមគ្រួសារ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចជូនជាតិ មាតុភូមិ និងប្រជាជនជាទីស្រឡាញ់នៃយើង។

ខ្ញុំបាទសូមគោរពអញ្ជើញ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាថ្លែងសុន្ទរកថាគន្លឹះបើក «សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨» ដោយសេចក្តីអនុគ្រោះ។

***សូមអរគុណ!***